

## ជំពូកទី១

# ភាពលំបាកក្នុងការស្តាប់ និងការប្រាស្រ័យទាក់ទង

នៅក្នុងពិភពលោកយើងទាំងមូល មានកុមារជាច្រើនដែលថ្លង់ ឬក៏អាចស្តាប់ឮបានតិចតួចបំផុត (ធ្ងន់ត្រចៀក)។ ឪពុកម្តាយអាចនឹងមិនដឹងនូវមូលហេតុ ដែលបណ្តាលឱ្យកូនរបស់ពួកគាត់ក្លាយទៅជាថ្លង់។ ភាពថ្លង់អាចជាលទ្ធផលដែលបណ្តាលមកពីដំបៅត្រចៀក ជំងឺដូចជា រលាកស្រោមខួរ របួស ឬក៏តំណពូជ។ សំរាប់ព័តិមានបន្ថែមអំពីមូលហេតុនៃភាពថ្លង់ សូមអានជំពូកទី15។



កុមារថ្លង់ ឬមិនអាចស្តាប់ឮល្អត្រូវការសេចក្តីស្រឡាញ់ ការយកចិត្តទុកដាក់ មិត្តភាព ចំណែកនៃអ្វីមួយ និងការអប់រំដូចកុមារគ្រប់ៗរូបផងដែរ។ ដោយសារពួកគេស្តាប់មិនឮ កុមារទាំងនេះមិនអាចរៀនភាសាដោយគ្មានការជួយជ្រោមជ្រែងបានទេ បើសិនជាគ្មានភាសា ពួកគេមិនអាចប្រាស្រ័យទាក់ទងជាមួយមនុស្សឯទៀត សំដែងអារម្មណ៏របស់ខ្លួន ឬរៀនសូត្របានងាយស្រួលដូចកុមារដទៃទៀតឡើយ។

ប៉ុន្តែការជួយឱ្យទាន់ពេលវេលា (ពេលដឹងថាទារក ឬកុមារតូចស្តាប់មិនឮល្អ) អាចឱ្យកុមារថ្លង់រៀនភាសាបានល្អដូចកុមារគ្រប់គ្នាឯទៀតអញ្ចឹងដែរ។ ដូច្នេះធនធានដ៏សំខាន់ៗសំរាប់ជួយកុមារថ្លង់ គឺឪពុកម្តាយ សមាជិកគ្រួសារ និងមិត្តភ័ក្តដែលចំណាយពេលដើម្បីជួយពួកគេរៀន និងឈានទៅរកការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃបាន។

ជាមួយការគាំទ្រ គ្រួសារទាំងឡាយនៃកុមារដែលមានលទ្ធភាពស្តាប់ឮខុសៗគ្នាអាចធ្វើឱ្យផ្ទះ និងសហគមន៏ ក្លាយជាកន្លែងដែលកូនៗរបស់ពួកគេត្រូវបានរាប់រក ហើយភាពរឹងប៉ឹងរបស់កុមារទាំងនោះត្រូវបានទទួលស្គាល់ កុមារអាចបង្កើតមិត្តភក្តិ រៀនសូត្រ និងរស់នៅយ៉ាងសប្បាយរីករាយ។



## 2 ភាពលំបាកក្នុងការស្តាប់ និងការប្រាស្រ័យទាក់ទង

## ហេតុអ្វីការប្រាស្រ័យទាក់ទងមានសារៈសំខាន់?

កុមាររៀនភាសាបានយ៉ាងរហ័សក្នុងឆ្នាំដំបូងនៃជីវិតរស់នៅ។ ជាការសំខាន់ បញ្ហាការស្តាប់របស់កុមារត្រូវតែបានដឹងភ្លាមៗឱ្យទាន់ពេលវេលា ដើម្បីឱ្យកុមារទទួលបានជំនួយដ៏មានប្រសិទ្ធភាព។ បើសិនកុមារមិនត្រូវបានជួយឱ្យទាន់ពេលទេ ពេលវេលាល្អបំផុត សំរាប់រៀនបំណិនប្រាស្រ័យទាក់ទង (ចាប់ពីថ្ងៃកើតដល់អាយុ7ឆ្នាំ) អាចត្រូវបាត់បង់។

**ការប្រាស្រ័យទាក់ទងគ្នា**កើតឡើងទៅបាន ដរាបណាយើង**យល់**ពីអ្វីដែលមនុស្សម្នានិយាយ និងឆ្លើយមករកយើង នៅពេលយើងបញ្ចេញគំនិត តម្រូវការ និងអារម្មណ៍របស់យើងយ៉ាងណា ឱ្យគេឯងបានយល់វិញផងដែរ។

កាលណាកុមារចាប់ផ្តើមរៀនភាសាមួយកាន់តែឆាប់ទាន់អាយុនៅតិច និងហាត់ការប្រាស្រ័យទាក់ទង នោះកុមារអាចរៀនបានកាន់តែច្រើន។

## ភាពឯកោរបស់កុមារថ្លង់



សំរាប់កុមារម្នាក់ដែលថ្លង់ ការរស់នៅហាក់ដូចជាស្ថិតនៅក្នុងបន្ទប់មានជញ្ជាំងកញ្ចក់ព័ទ្ធជុំវិញ។ កុមារថ្លង់អាចមើលឃើញមនុស្សម្នានិយាយគ្នា ប៉ុន្តែកុមារថ្លង់មិនអាចយល់នូវអ្វីៗដែលមនុស្សទាំងនោះកំពុងនិយាយគ្នាបានឡើយ។

មនុស្សម្នាទាំងឡាយអាចឆ្លើយឆ្លងនឹងគ្នាទៅវិញទៅមកបាន ពីព្រោះពួកគេបានរៀនភាសាមួយដើម្បីធ្វើការប្រាស្រ័យទាក់ទងគ្នា។ តែកុមារថ្លង់មិនអាចរៀនភាសាមួយ ដែលពួកគេមិនអាចស្តាប់ឮនោះបានទេ។ នេះមានន័យថា កុមារថ្លង់ភាគច្រើន ធំដឹងក្តីឡើងដោយមិនបានរៀន ឬមិនបានប្រើភាសាមួយដើម្បីឆ្លើយឆ្លងជាមួយមនុស្សម្នានៅជុំវិញពួកគេ។

មនុស្សយើងត្រូវការការប្រាស្រ័យទាក់ទងយ៉ាងខ្លាំង និងកសាងចំណងទាក់ទងជាមួយគ្នាទៅវិញទៅមក។ នៅពេលកុមារគ្មានបំណិនប្រាស្រ័យទាក់ទងដើម្បីផ្សារភ្ជាប់ទៅមនុស្សឯទៀត និងពេលមនុស្សឯទៀតមិនដឹងរបៀបប្រាស្រ័យទាក់ទង ឬផ្សារភ្ជាប់ជាមួយកុមារថ្លង់ នោះកុមារថ្លង់អាចត្រូវបានទុកចោលម្នាក់ឯងស្ទើរតែគ្រប់ពេល ទោះបីជានៅក្បែរមនុស្សដែលជិតស្និទ្ធបំផុតនឹងខ្លួនក៏ដោយ។ គ្រាក្រោយមកកុមារថ្លង់នោះ នឹងត្រូវបាននៅដាច់ឆ្ងាយពីគេឯង។






## ការប្រាស្រ័យទាក់ទងសំរាប់ការសិក្សា  និងការគិត

កុមារប្រើការប្រាស្រ័យទាក់ទងដើម្បីរៀនអំពីព្រឹត្តិការណ៍ទាំងឡាយដែលនៅជុំវិញ ដើម្បីផ្សារភ្ជាប់ខ្លួនគេទៅមនុស្សឯទៀត សំដែងពីអារម្មណ៍របស់គេ គិត និងអភិវឌ្ឍគំនិតរបស់ពួកគេ ។ បើគ្មានទម្រង់ណាមួយនៃការប្រាស្រ័យទាក់ទង កុមារថ្លង់ម្នាក់មិនអាចលូតលាស់បញ្ញាស្មារតី ឬលទ្ធភាពទាំងឡាយរបស់ខ្លួនបានពេញលេញឡើយ ។



កាលណាកុមាររៀនភាសាមួយបានកាន់តែច្រើន នោះពួកគេកាន់តែយល់ពីស្ថានភាពរបស់ខ្លួន កាន់តែចេះគិត និងដាក់ផែនការ ហើយអភិវឌ្ឍចំណងទាក់ទងជិតស្និទ្ធជាមួយមនុស្សនៅជុំវិញខ្លួនបានច្រើនតាមនោះដែរ ។

សំរាប់ព័ត៌មានអំពីភាសា និងការអភិវឌ្ឍរបស់កុមារ សូមអានជំពូកទី2 ។





ខ្ញុំនឹងជំរាបអ្នកពីរឿងរ៉ាវរបស់ខ្ញុំ ដំបូងខ្ញុំនឹងប្រាប់អ្នកពីរឿងរ៉ាវរបស់កុមារមិនអាចស្តាប់ឮ។ កុមារគ្រប់គ្នាមិនបានទៅសាលារៀនដូចខ្ញុំនោះទេ។ ***អានីតា*** ជាមនុស្សថ្លង់ដូចខ្ញុំដែរ តែនាងមិនបានរៀនអំពីការប្រាស្រ័យទាក់ទងនោះទេ។ នេះជារឿងរបស់***អានីតា***។

## រឿងរ៉ាវរបស់កុមារី អានីតា

***អានីតា*** ពេលកើតមកស្ទើរតែថ្លង់ទាំងស្រុង តែឪពុកម្តាយនាងមិនបានចាប់អារម្មណ៍រហូតដល់នាងមានអាយុ 4ឆ្នាំ។ កាលពីនាងនៅជាទារក ពួកគាត់ឃើញថានាងមានសុខភាពល្អនិងស្វាហាប់។ រហូតពេល***លរ៉ា*** ប្អូនស្រីនាងកើតមក ក៏ពួកគាត់មិនព្រួយបារម្ភថា***អានីតា***មិនទាន់ចេះនិយាយដែរ។ ពួកគាត់គិតថានាងប្រហែលលូតលាស់យឺតបន្តិច។

នៅថ្ងៃមួយអ្នកជិតខាងម្នាក់បានសួរ "តើអ្នកបងដឹងច្បាស់ហើយឬថានាងអាចស្តាប់ឮ?"។ "អូ! ចាស៎" ម្តាយនាងឈ្មោះ***អេវ៉ា*** បានឆ្លើយទៅវិញ។ អេវ៉ាបានហៅឈ្មោះ***អានីតា***យ៉ាងខ្លាំង ហើយនាងក៏បានងាកក្បាលមករក។

ពេលនាងមានអាយុ3ឆ្នាំ ***អានីតា***អាចនៅនិយាយបានតែពីរបីម៉ាត់ប៉ុណ្ណោះ។ ***លរ៉ា*** ជាប្អូនស្រីរបស់***អានីតា*** មានអាយុ2ឆ្នាំ ចេះនិយាយពាក្យថ្មីៗរាល់ថ្ងៃ។ ***លរ៉ា***ញញឹម និងលេងសើចបានច្រើនជាង ***អានីតា*** ពេលម្តាយបាននិយាយ ឬច្រៀងទៅរកនាង។ ដូច្នេះ***អេវ៉ា*** បាននិយាយ និងច្រៀងទៅរក***លរ៉ា***ច្រើនជាង***អានីតា***។ ***លរ៉ា***បានសួររករបស់របរ ចេះច្រៀងចម្រៀងសាមញ្ញៗ និងបានលេងកំសាន្តជាមួយក្មេងៗឯទៀត។ ***អានីតា***លេងតែម្នាក់ឯងដោយសារពេលនាងលេងជាមួយក្មេងៗឯទៀត ភាគច្រើននាងតែងយំ និងឈ្លោះគ្នា។



ពេលមួយនោះ នៅឯផ្សារក្នុងភូមិ ***លរ៉ា***បានសុំទិញខ្សែចងសក់ ហើយ***អេវ៉ា***បានទិញខ្សែចងសក់មួយឱ្យនាង។ មួយស្របក់ក្រោយមក ***អានីតា***បានរើសយកខ្សែរចងសក់មួយទៀតដោយស្ងៀមស្ងាត់ និងចាប់ផ្តើមចងសក់ខ្លួនឯង។ ***អេវ៉ា***មានការអៀនខ្មាស និងអន់ចិត្តជាខ្លាំង គាត់ក៏បានយកខ្សែរចងសក់ពី***អានីតា***។ ***អានីតា***បោកនទៀលខ្លួនទៅលើដី ហើយចាប់ផ្តើមទធាក់ដី និងស្រែកខ្លាំងៗ។



ពេលឪពុក***អានីតា***បានដឹងរឿងកើតឡើងនៅផ្សារ គាត់មើលទៅ***អានីតា*** ដោយខឹងសម្បារ និងនិយាយថា "ពេលណាទៅទើបឯងចេះសួរដើម្បីសុំរបស់របរ? ឯងអាយុ4ឆ្នាំហើយ នៅតែមិនព្យាយាមនិយាយទៀត។ តើឯងភ្លើ ឬក៏ឯងខ្ជិល?" ***អានីតា***មើលទៅឪពុកនាងវិញ នាងមិនយល់នូវអ្វីៗដែលឪពុកបាននិយាយទាល់តែសោះ តែនាងបានយល់ទឹកមុខគាត់ខឹង។ ទឹកភ្នែកហូរចុះលើថ្ពាល់របស់នាង។ ឪពុកនាងបានបន្ទន់តិរិយាបថ និងឱបនាងក្នុងរង្វង់ដៃគាត់។

នៅល្ងាចនោះ ពេលក្រុមគ្រួសារអង្គុយជំនុំគ្នា ***អេវ៉ា*** នឹកឃើញដល់អ្នកជិតខាងដែលបានសួរគាត់ពីការស្តាប់ឮរបស់ ***អានីតា***។ ***អេវ៉ា*** បានសំរេចចិត្តព្យាយាមធ្វើសម្លេងនានា នៅពីក្រោយខ្នងរបស់ ***អានីតា*** ដើម្បីឱ្យដឹងថានាងអាចស្តាប់ឮឬទេ? នៅពេលក្រុមគ្រួសារបានឃើញថា ***អានីតា***មិនឆ្លើយតបទៅនឹងសម្លេងស្ទើរតែទាំងអស់ នោះពួកគេបានដឹងប្រាកដថា ***អានីតា***ពិតជាថ្លង់មែន ។ វាជាថ្ងៃដែលស្រពាប់ស្រពោនណាស់ សំរាប់ពួកគេទាំងអស់គ្នា ។

គ្រួសារ ***អានីតា***ព្រួយបារម្ភខ្លាចក្រែងនាងមិនអាចមានលទ្ធភាពកសាងខ្លួនដូចកុមារផ្សេងៗទៀតរហូតទៅ ។




ឳពុកម្តាយរបស់ ***អានីតា*** បានធ្វើអ្វីៗដែលប្រសើរបំផុតដើម្បីជួយនាង ។ ពួកគេរវល់ខ្លាំងណាស់ក្នុងការថែទាំកូនៗឯទៀត និងការងារស្រែចំការរបស់ខ្លួន ដូច្នេះជាការលំបាកសំរាប់ពួកគេក្នុងការផ្តល់ការយកចិត្តទុកដាក់ដែល ***អានីតា***ត្រូវការ ។ ឳពុកម្តាយនាងសង្ឃឹមថាថ្ងៃណាមួយ ***អានីតា***នឹងមានជីវិតរស់នៅពេញលេញមួយ ប៉ុន្តែពួកគេមិនដឹងធ្វើបែបណាអាចជួយនាងបាន ។



***អានីតា***មិនមែនជាក្មេងល្ងង់ទេ ។ ពីព្រោះគ្មាននរណាម្នាក់បង្រៀនភាសាដល់នាង និងរៀនប្រាស្រ័យទាក់ទងជាមួយនាង ។ ***អានីតា*** និងអ្នកដែលនៅជុំវិញនាង ជាញឹកញាប់មិនយល់គ្នា និងមានការអាក់អន់ចិត្តគ្នាទៅវិញទៅមក ។

***អានីតា*** និងកុមារថ្លង់ផ្សេងៗទៀតអាចសំដែងអាកប្បកិរិយាអាក្រក់ៗ ដោយសារពួកគេមិនយល់ដឹងនូវអ្វីៗដែលគួរធ្វើ ។ ពីព្រោះ ***អានីតា***មិនអាចស្តាប់ឮពាក្យពេជន៏បានច្បាស់លាស់ ជាការពិបាកយ៉ាងខ្លាំងសំរាប់នាង ដើម្បីរៀនភាសានៃក្រុមគ្រួសារ ។ ដូច្នេះនាងមានបញ្ហាមិនយល់នូវអ្វីៗដែលមនុស្សម្នាចង់បាន ហើយក៏មិនអាចប្រាប់ទៅពួកគេនូវអ្វីដែលនាងចង់បាន ។

ពេលខ្លះកុមារមិនអាចស្តាប់ឮមានអារម្មណ៏ឯកោ ឬភ្លេចភ្លាំង និងកើតមាន "វិបត្តិអាកប្បកិរិយា" ឬក៏ការលូតលាស់យឺតក្នុងការរៀនផ្សារភ្ជាប់ខ្លួនទៅមនុស្សផ្សេងៗទៀត វាមិនជាអ្វីគួរឱ្យភ្ញាក់ផ្អើលចំពោះពួកគេឡើយ ។ ***អានីតា***ត្រូវការជំនួយដើម្បីរៀនភាសា ធ្វើដូច្នេះនាងអាចយល់បានពីព្រឹត្តិការណ៏ទាំងឡាយនៅជុំវិញខ្លួននាង ។



នេះជារឿងរបស់កុមារា***ឱម៉ា***។ នៅពេលកើតមក***ឱម៉ា*** មិនថ្លង់នោះទេ។

***ឱម៉ា***បានបាត់បង់ការស្តាប់ពេលរៀននិយាយ។

## រឿងរ៉ាវរបស់កុមារា ឱម៉ា

កុមារា***ឱម៉ា*** បានកើតមកដោយស្តាប់ឮធម្មតា និងជាក្មេងប្រុសដែលនិយាយប៉ប៉ាច់ប៉ប៉ោច ច្រើន។ ប្រហែលជាពីរបីឆ្នាំ ***ឱម៉ា***បានកើតរោគដំបៅត្រចៀកជាច្រើនដង។ គ្រួសាររបស់***ឱម៉ា***មិនមានលទ្ធភាពទិញថ្នាំព្យាបាលត្រចៀក។ ពេលដំបៅត្រចៀកម្តងៗ ***ឱម៉ា***បានបាត់បង់ការស្តាប់ឮបន្តិចម្តងៗ។ នៅពេល***ឱម៉ា***មានអាយុ 4ឆ្នាំ ក្មេងនេះលែងយល់នូវអ្វីៗដែលឪពុកម្តាយបាននិយាយមករកគេ។ ***ឱម៉ា***គ្រាន់តែមើលទៅឪពុកម្តាយវិញដោយការងឿងឆ្ងល់ រីឯការនិយាយរបស់គេកាន់តែតិចទៅៗ។




ជីតារបស់***ឱម៉ា***បានបាត់បង់ការស្តាប់ឮមួយភាគធំ ដោយសារវ័យចាស់ជរា គាត់ផ្តល់យោបល់ខ្លះៗ ដែលប្រហែលជាអាចជួយ***ឱម៉ា***បាន។ លោកតាមានប្រសាសន៍ថា គាត់អាចយល់មនុស្សនិយាយគ្នាបានសមល្មម ដោយប្រើប្រាស់ការស្តាប់ឮនៅសេសសល់ និងដោយមើលមាត់មនុស្សនិយាយគ្នា។ ប៉ុន្តែជីតារបស់***ឱម៉ា***បានពោលបន្តទៀតថា ពេលខ្លះគាត់មានការពិបាកយល់មនុស្សនិយាយ ដោយសារពាក្យពេជន៍ដូចៗគ្នាពេកនៅលើបបូរមាត់។ លោកតាសញ្ជឹងគិតថា ឧបករណ៍ជំនួយការស្តាប់ប្រហែលអាចជួយ***ឱម៉ា***បាន។

ឪពុក***ឱម៉ា***បានយកកូនប្រុសទៅគ្លីនិកនៅទីក្រុង ដែលជួយផ្នែកការស្តាប់។ មនុស្សនៅទីនោះបានធ្វើតេស្ត***ឱម៉ា*** និងគិតថាឧបករណ៍ជំនួយការស្តាប់នឹងអាចជួយក្មេងនេះបាន។ ឪពុក***ឱម៉ា***បានខ្ចីលុយពីបងប្អូនជីដូនមួយ ហើយ***ឱម៉ា***បានពាក់ឧបករណ៍ជំនួយការស្តាប់។ ក្រុមគ្រួសារបានហាត់និយាយជាមួយ***ឱម៉ា*** ជួយកូនឱ្យយល់អំពីពាក្យ និងការនិយាយឱ្យបានត្រឹមត្រូវ។ ដោយសារ***ឱម៉ា***នៅក្មេងខ្ចី ឧបករណ៍ជំនួយការស្តាប់ត្រូវការបំណែកផ្លាស់ប្តូរជាច្រើន ពេលដែល***ឱម៉ា***(និងត្រចៀក) កាន់តែលូតលាស់ធំឡើងៗ។

កុមារមួយចំនួនដូចជា ***ឱម៉ា***អាចនៅស្តាប់ឮខ្លះៗ ប្រហែលជាមានលទ្ធភាពនិយាយ និងអានដោយមើលមាត់មនុស្សនិយាយគ្នា។ ឧបករណ៍ជំនួយការស្តាប់អាចជួយដល់***ឱម៉ា*** ពីព្រោះគេអាចនៅស្តាប់ឮខ្លះៗ។ ជាជំនួយផងដែរ ដែល***ឱម៉ា***បានយល់ដឹងភាសាមុនពេលក្លាយជាថ្លង់។



ឪពុកម្តាយ***ឱម៉ា*** ប្រហែលជាប្រឈមមុខនឹងការរកលុយទិញថ្ម និងបំណែកថ្មីៗសំរាប់ផ្លាស់ប្តូរឧបករណ៍ជំនួយការស្តាប់ ពេល***ឱម៉ា***មានវ័យធំទៅៗ។ បើសិនជាពួកគេអាចធ្វើដូច្នេះបាន ***ឱម៉ា***នឹងបានល្អប្រសើរតទៅ។



នេះជារឿងរបស់***ជូលីយ៉ា***។ នៅពេលឪពុកម្តាយរបស់***ជូលីយ៉ា***បានដឹងថា នាងថ្លង់ ពួកគេបានបង្កើតសញ្ញាសំរាប់ប្រើប្រាស់ជាមួយនាង។

## រឿងរ៉ាវរបស់កុមារី ជូលីយ៉ា

***អ៊ីរ៉ែន*** និង***ភីតជ្រូ*** បានដឹងប្រាកដថាកូនស្រីរបស់ពួកគេឈ្មោះ***ជូលីយ៉ា*** ជាក្មេងថ្លង់ ពេលក្មេងឯទៀតអាយុស្រករនាងចេះនិយាយ តែនាងនៅមិនទាន់ចេះនិយាយទៀត។ ***អ៊ីរ៉ែន***បានប្តេជ្ញាថា ***ជូលីយ៉ា***នឹងមានគ្រប់ឱកាសរៀនសូត្រ និងទទួលបានជោគជ័យក្នុងជីវិត។ ទោះបីជាមានការសង្ស័យ ខ្លាចក្រែង និងមានរឿងត្រូវគិតជាច្រើនក្តី ក៏***អ៊ីរ៉ែន***បានគិតថា "***ជូលីយ៉ា***គ្រាន់តែស្តាប់មិនឮ មិនមានន័យថា នាងមិនអាចរៀនធ្វើអ្វីៗនោះទេ" ។

***អ៊ីរ៉ែន***នឹកឃើញពេលមួយ ខ្លួនគាត់បានជួបស្ត្រីម្នាក់និយាយភាសាមួយផ្សេងគ្នា។ ក្នុងពេលពួកគេនិយាយគ្នាមិនយល់ ពួកគេបានប្រើកាយវិការ និងសំដែងសកម្មភាពទាំងឡាយដែលពួកគេចង់និយាយ។ ទោះបីជាចំណាយពេលច្រើនបន្តិច និងជួនកាលមិនយល់គ្នាទៅវិញទៅមកក៏ដោយ តែពួកគេមានការពេញចិត្ត។

ដូច្នេះដើម្បីប្រាស្រ័យទាក់ទងជាមួយ***ជូលីយ៉ា*** ក្រុមគ្រួសារទាំងមូលបានបង្កើតកាយវិការ និង "សញ្ញាប្រចាំផ្ទះ" ហើយបានប្រើទាំងអស់គ្នា សូម្បីញាតិជិតខាងក៏បានចាប់ផ្តើមរៀនរបៀបប្រើសញ្ញាប្រចាំផ្ទះរបស់***ជូលីយ៉ា***ផងដែរ។




បន្ទាប់មក ***អ៊ីរ៉ែន***បានសួរទៅអ្នកគ្រូម្នាក់ក្នុងភូមិថា ពេលណាទើប***ជូលីយ៉ា***អាចចាប់ផ្តើមចូលរៀនបាន។ អ្នកគ្រូនោះបានប្រាប់ថា គាត់គ្មានវិធីណាអាចបង្រៀនក្មេងថ្លង់បានឡើយ។ អ្នកគ្រូបានប្រាប់ ***អ៊ីរ៉ែន*** ពីសាលារៀនដែលប្រហែលជាអាចជួយបង្រៀនដល់***ជូលីយ៉ា***បាន ប៉ុន្តែត្រូវដើរទៅទីនោះរយៈពេលពីរម៉ោង និងត្រឡប់មកវិញក្នុងរយៈពេលដូចគ្នា។ ***អ៊ីរ៉ែន*** និង***ភីតជ្រូ***បានសញ្ជឹងគិតថា តើ***ជូលីយ៉ា***មានអាយុប៉ុន្មាន ទើបនាងអាចទៅរៀននៅទីនោះបានដោយខ្លួនឯងរាល់ថ្ងៃ។

បំណងប្រាថ្នាក្នុងការប្រាស្រ័យទាក់ទងរបស់មនុស្ស គឺមានខ្លាំងក្លាណាស់។ នៅពេលដែលឪពុកម្តាយចេះរបៀបប្រាស្រ័យទាក់ទងដោយធ្វើកាយវិការ និងធ្វើសញ្ញាប្រចាំផ្ទះ កុមារីតូចដូចជា***ជូលីយ៉ា*** អាចលូតលាស់ក្លាយជាកុមារីឆ្លាតវាងវៃ ហើយសប្បាយរីករាយ។



កុមារគ្រប់រូបមានសិទ្ធិទទួលការអប់រំ! តើ***ជូលីយ៉ា***អាចបន្តការសិក្សារបៀបណាទៅ? ដោយសារតែមានការផ្លាស់ប្តូរនៅប្រទេសរបស់ខ្ញុំ ទើបខ្ញុំមានឱកាសបានទៅសាលារៀន។



មុនពេលខ្ញុំជំរាបពីរឿងរបស់ខ្ញុំ អ្នកត្រូវដឹងជាមុនអំពីប្រទេសនីការ៉ាហ្គ័រ គឺជាប្រទេសនៅទ្វីបអាមេរិកកណ្តាល ជាកន្លែងដែលខ្ញុំរស់នៅ និងមានហេតុការណ៍យ៉ាងណាខ្លះ កាលពីពេលដែលខ្ញុំធំឡើង ។

## ការអប់រំសំរាប់កុមារពិការនៅប្រទេសនីការ៉ាហ្គ័រ

អស់រយៈពេលជាច្រើនឆ្នាំ ប្រទេសនីការ៉ាហ្គ័រត្រូវបានត្រួតត្រាអំណាចដោយគ្រួសារ***សូម៉ូសា***។ ពួកគេក្តោបក្តាប់ភោគទ្រព្យនៃប្រទេសស្ទើរតែទាំងអស់ និងបានផ្តល់សេវាកម្មតិចតួចដល់ប្រជាជន ។ ***សូម៉ូសា*** មិនបានគិតពិចារណាពីសារៈសំខាន់នៃការអប់រំសំរាប់ប្រជាជនឡើយ ។ ពួកគេយល់ថាប្រជាជនត្រូវចំណាយពេលរស់នៅដើម្បីធ្វើស្រែចំការ មិនត្រូវការទៅសាលារៀននោះទេ ។ ***សូម៉ូសា*** ខ្លួនឯងបាននិយាយថា "ខ្ញុំមិនចង់បានមនុស្សចេះដឹងទេ ខ្ញុំចង់បានតែសត្វគោ!"



ជាលទ្ធផល ប្រជាជនស្ទើរតែទាំងអស់ក្នុងប្រទេសនីការ៉ាហ្គ័រ មិនចេះអានឬសរសេរឡើយ ។ កុមារជាច្រើន :- ទាំងក្រីក្រ ទាំងពិការ ស្ទើរតែទាំងអស់នៅតំបន់ជនបទ ជាពិសេសកុមារថ្លង់មិនអាចទៅសាលារៀន ។



មនុស្សមានអំណាច តែងមានអាកប្បកិរិយាងាយចាត់ទុកមនុស្សដែលខុសពីខ្លួន ជាមនុស្សមានសិទ្ធិតិចតួច និងមិនសមជាមនុស្ស ។ ករណីនេះ បានកើតឡើងចំពោះជនក្រីក្រ ជននិយាយភាសាប្លែកពីគេ ស្ត្រី និងជនដែលអនុវត្តសាសនាមួយប្លែកពីគេ ជាពិសេសជនពិការ ។

បន្ទាប់មកនៅឆ្នាំ 1979 ប្រជាជននីការ៉ាហ្គ័របានផ្តួលរំលំអំណាចផ្តាច់ការរបស់***សូម៉ូសា*** ហើយបាននាំមកនូវរដ្ឋាភិបាលថ្មីមួយ ។ រដ្ឋាភិបាលថ្មីមានជំនឿជឿជាក់ថា មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការអប់រំ និងបានធ្វើឱ្យប្រព័ន្ធការអប់រំមានដល់កុមារគ្រប់រូប រួមទាំងកុមារថ្លង់ ។ ជាលើកដំបូងនៅប្រទេសនីការ៉ាហ្គ័រ សាលារៀនសំរាប់កុមារថ្លង់ត្រូវបានបើកឱ្យសិក្សារៀនសូត្រ ។




នៅពេលមនុស្សគ្រប់រូបបានប្តេជ្ញាចិត្តចំពោះការអប់រំ កុមារថ្លង់អាចមានភ័ព្វសំណាងបានរៀនសូត្រ ទៅសាលារៀន និងបានអភិវឌ្ឍលទ្ធភាពទាំងឡាយរបស់ពួកគេ ដូចមនុស្សទូទៅគ្រប់គ្នាដែរ!

## រឿងរ៉ាវរបស់នាង ខារ៉មែន

ក្រោយពីខ្ញុំកើតមកបានប៉ុន្មានខែ ជំងឺឆ្លងមួយបានរាតត្បាតយ៉ាងលឿនតាមរយៈក្មេងៗនៅក្នុងភូមិ ។ ខ្ញុំក៏បានឈឺដែរ ជាជំងឺគ្រុនក្តៅសន្ធំ ។ ឪពុកម្តាយខ្ញុំត្រេកអរខ្លាំងណាស់ពេលខ្ញុំបានគ្រាន់បើ ប៉ុន្តែពួកគាត់បានដឹងប្រាកដថា ជំងឺនោះបានបន្សល់ឱ្យខ្ញុំនូវភាពថ្លង់ ។ ពេលខ្ញុំធំបន្តិច យើងទាំងអស់គ្នាមានអារម្មណ៍តឹងតែង ពីព្រោះការប្រាស្រ័យទាក់ទងគ្នាមានការពិបាកខ្លាំងពេក សូម្បីតែគំនិត ឬតម្រូវការសាមញ្ញមួយក៏ដោយ ។ គ្រួសារខ្ញុំមិនដឹងពីរបៀបប្រាស្រ័យទាក់ទងជាមួយខ្ញុំ ឬក៏របៀបបង្រៀនខ្ញុំឡើយ ។

បើខ្ញុំចង់បានអ្វីមួយ ខ្ញុំត្រូវតែបង្ហាញក្រុមគ្រួសារខ្ញុំដោយចង្អុលទៅរបស់នោះ ។
បើគ្មានរបស់នៅទីនោះទេ ខ្ញុំមិនអាចធ្វើឱ្យពួកគេយល់បានឡើយ ។





ក្រោយពេលបដិវត្តន៍នៅប្រទេសនីការ៉ាហ្គ័រ សាលារៀនសំរាប់កុមារថ្លង់បានបើកឡើង ឪពុកម្តាយខ្ញុំបាននាំខ្ញុំទៅកាន់ទីនោះ ។ ពួកគាត់បានដឹងថា សាលារៀនអាចជួយខ្ញុំនូវវិធីនានា ដែលពួកគាត់មិនអាចជួយបាន ។ គ្រូបង្រៀននៅសាលារៀន បានព្យាយាមបង្រៀនយើងគ្រប់គ្នាឱ្យចេះអានដោយមើលមាត់ និងនិយាយ ។ ទោះបីជាពួកយើងជាច្រើនមិនអាចចេះអានដោយមើលមាត់ និងនិយាយមិនទាន់ល្អក៏ដោយ គ្រាន់តែយើងបាននៅជាមួយគ្នា អ្វីៗទាំងឡាយនៅជុំវិញបានចាប់បើកចំហរសំរាប់ពួកយើង ។



ពីមុនមក ខ្ញុំមិនដែលស្គាល់ក្មេងថ្លង់ណាម្នាក់សោះ ។ មិត្តរួមថ្នាក់ថ្មីៗរបស់ខ្ញុំ ក៏មិនធ្លាប់បានជួបក្មេងៗថ្លង់ដែរ ។ ពេលខ្ញុំឃើញក្មេងៗឯទៀតប្រើសញ្ញា ខ្ញុំក៏បានចាប់ផ្តើមប្រើវាដែរ ។
ជាលើកដំបូង ខ្ញុំបានចាប់ផ្តើមរៀនសូត្រ ។

ពួកយើងភាគច្រើន បានទៅសាលារៀនពេលមានអាយុច្រើនហើយ ។ យើងបានប្រាស្រ័យទាក់ទងគ្នាតាមរយៈ "សញ្ញាប្រចាំផ្ទះ" ដែលបានប្រើជាមួយក្រុមគ្រួសាររបស់យើង ហើយសុទ្ធតែខុសគ្នាទាំងអស់ ។ យើងបានបង្រៀនសញ្ញាទាំងនេះដល់គ្នាទៅវិញទៅមក និងបានរួមគ្នាបង្កើតសញ្ញាថ្មីៗ ។ វាជាការងាយស្រួលសំរាប់ពួកយើងប្រើសញ្ញាសំរាប់ប្រាស្រ័យទាក់ទងគ្នា ។ នៅពេលពួកយើងប្រើសញ្ញាបានកាន់តែច្រើនឡើងៗ វាបានក្លាយជាភាសាមួយពិត ។ យ៉ាងឆាប់រហ័ស យើងអាចប្រាស្រ័យទាក់ទងគ្នាបានច្រើនបែបទៅវិញទៅមក អំពីក្រុមគ្រួសារ និងមិត្តភ័ក្តិរបស់យើង ផែនការ និងក្តីសុបិន្តរបស់យើង និងអ្វីៗទាំងឡាយដែលបានកើតឡើងចំពោះយើង ។

## 10 ភាពលំបាកក្នុងការស្តាប់ និងការប្រាស្រ័យទាក់ទង

### ភាសាធ្វើឱ្យការរៀនសូត្រ និងសហគមន៍មានលទ្ធភាព

នាង***ខាមែន*** និងយុវជនថ្លង់ជាពលរដ្ឋនៃប្រទេសនីការ៉ាហ្គ័រ បានបង្ហាញភ័ស្តុតាងដល់ពិភពលោកថា ភាសាសញ្ញាគឺជាភាសាធម្មជាតិ និងជាភាសាពេញលេញដែលបានអភិវឌ្ឍក្នុងសហគមន៍ ។ ដូចភាសាដទៃទៀតដែរ ដើម្បីប្រើភាសាសញ្ញា អ្នកត្រូវការមនុស្សមួយក្រុមដើម្បីប្រើប្រាស់វា ។

ខណៈដែល***ខាមែន*** និងកុមារឯទៀតបានអភិវឌ្ឍភាសាសញ្ញានីការ៉ាហ្គ័រ និងបំណិនប្រាស្រ័យទាក់ទង ពួកគេក៏បានអភិវឌ្ឍលទ្ធភាពទាំងឡាយផងដែរ ដើម្បីរៀបរាប់អំពីវត្ថុនានា ដោះស្រាយបញ្ហា និងកើតមានអារម្មណ៍ តម្រូវការ និងគំនិតយល់ដឹង ។ ភាសាសញ្ញាមិនត្រឹមតែអាចផ្តល់ឱ្យកុមារនូវវិធីដើម្បីប្រាស្រ័យទាក់ទងប៉ុណ្ណោះទេ វាក៏បានជួយអភិវឌ្ឍលទ្ធភាពកុមារឱ្យចេះគិតផងដែរ ។



ភាសាសញ្ញាអាចឱ្យខ្ញុំនិយាយជាមួយមនុស្សឯទៀត រៀនពីអ្វីៗទាំងឡាយដែលនៅជុំវិញ និងនិយាយនូវអ្វីដែលខ្ញុំគិត ។ ខ្ញុំមិននៅឯកោ អារម្មណ៍តឹងតែង ឬច្របូកច្របល់ម្នាក់ឯងទៀតឡើយ ។ ភាសាសញ្ញាគឺជាភាសារបស់ខ្ញុំ អាចឱ្យខ្ញុំក្លាយជាចំណែកមួយនៃសហគមន៍ ។

### ការទទួលយកភាពខុសប្លែក អាចនាំមនុស្សឱ្យចេះសាមគ្គីគ្នា

មនុស្សថ្លង់ គឺខុសប្លែកពីគេត្រង់ការយល់ដឹង និងភាសាដែលពួកគេប្រាស្រ័យទាក់ទងគ្នា និងបង្ហាញឱ្យគេឯងបានដឹងឮអំពីពួកគេ ។ ជាជាងធ្វើពើ មិនដឹងថាគ្មានភាពខុសប្លែក ការទទួលយកភាពខុសប្លែកនោះ គឺជាសម្បជញ្ញៈដ៏ត្រឹមត្រូវ ហើយប្រើប្រាស់វាដើម្បីនាំមនុស្សឱ្យចេះរួបរួមគ្នា ។ មនុស្សស្តាប់ឮជាច្រើនបាននិយាយថា មនុស្សថ្លង់បានជួយឱ្យពួកគេ "កក់ក្តៅច្រើន" និងហ៊ានបញ្ចេញគំនិតច្រើន ចំពោះរបៀបដែលពួកគេផ្សារភ្ជាប់ទៅមនុស្សឯទៀត ។

កុំងាកចេញ ខ្ញុំមិនអៀនខ្មាសទេ ។ ខ្ញុំមានមោទនភាព ជាមនុស្សថ្លង់!





ហេតុផលមួយដែលកុមារនីការ៉ាហ្គ័រ បានអភិវឌ្ឍភាសាមួយដ៏ពេញលេញនោះ គឺមានកុមារជាច្រើនប្រើប្រាស់វា ។ ពួកគេអាចធ្វើដូច្នេះបានដោយសារតែប្រជាជននៃប្រទេសនីការ៉ាហ្គ័របានសំរេចចិត្តដាក់ធនធានរបស់ពួកគេថែមទៀតទៅក្នុងការអប់រំ ។ ពួកគេបានចាប់ផ្តើមចលនាកំណែទម្រង់ប្រព័ន្ធការអប់រំ បានកែច្នៃប្រព័ន្ធសាលារៀនដ៏ខ្លាំងមួយសំរាប់កុមារគ្រប់រូប រួមបញ្ចូលទាំងកុមារថ្លង់ ឬកុមារស្តាប់ឮមិនល្អ (ធ្ងន់ត្រចៀក) ផងដែរ ។

## ការចូលរួមទាំងអស់គ្នាដើម្បីសិទ្ធិមនុស្សថ្លង់

សូមថ្លែងអំណរគុណដល់ការតស៊ូរបស់ប្រជាជននីការ៉ាហ្គ័រ ដែលបង្កើតឱ្យមានការអប់រំដល់មនុស្សគ្រប់រូប ក្មេងថ្លង់រាប់រយនាក់ត្រូវបាននាំចូលសាលារៀនជាលើកទីមួយ។ ក្នុងមួយជំនាន់ៗ កុមារចាប់ផ្តើមបង្កើតទម្រង់នៃការប្រាស្រ័យទាក់ទងថ្មី ហើយប្លែកដែលអភិវឌ្ឍនៅក្នុងភាសាសញ្ញានីការ៉ាហ្គ័រ។

នៅពាក់កណ្តាលឆ្នាំ1980 មនុស្សថ្លង់ពេញវ័យបានចាប់ផ្តើមប្រជុំ និងធ្វើការងារលើកកំពស់សិទ្ធិរបស់ពួកគេជាមនុស្សថ្លង់។ ពួកគេបានបង្កើតសមាគមជាតិនៃមនុស្សថ្លង់របស់ប្រទេសនីការ៉ាហ្គ័រ។ ប្រជាជនរបស់សមាគមជាតិនៃមនុស្សថ្លង់ប្រទេសនីការ៉ាហ្គ័រ បានជួយអភិវឌ្ឍលើកកំពស់ភាសាសញ្ញានីការ៉ាហ្គ័រ និងបានបោះពុម្ពវចនានុក្រម ក៏ដូចជាសៀវភៅសំរាប់កុមារផងដែរ។ ពួកគេបានធ្វើការជាមួយក្រសួងអប់រំ ដើម្បីចាប់ផ្តើមដាក់បញ្ចូលការធ្វើសញ្ញាទៅក្នុងសាលារៀននៃមនុស្សថ្លង់ និងធ្វើឱ្យប្រសើរឡើងដល់កម្មវិធីអប់រំសំរាប់មនុស្សថ្លង់។

សព្វថ្ងៃនេះ សមាគមជាតិនៃមនុស្សថ្លង់នីការ៉ាហ្គ័រ គឺជាក្រុមមួយដ៏មានអំណាចនៅក្នុងប្រទេសនីការ៉ាហ្គ័រ ដែលធ្វើការងារសំរាប់សិទ្ធិមនុស្សថ្លង់ និងជាមជ្ឈមណ្ឌលសង្គមមួយសំរាប់បំរើសមាជិករបស់ខ្លួន។



## 12 ភាពលំបាកក្នុងការស្តាប់ និងការប្រាស្រ័យទាក់ទង

# កុមារគ្រប់រូបអាចរៀនសូត្រដើម្បីប្រាស្រ័យទាក់ទងគ្នា

កុមារដែលមានលទ្ធភាពខុសៗគ្នាក្នុងការស្តាប់ឮ អាចប្រាស្រ័យទាក់ទងគ្នាដោយកាយវិការ ធ្វើសញ្ញាប្រចាំផ្ទះ ប្រើភាសាសញ្ញាពេញលេញ រៀនអានដោយមើលមាត់ និងការនិយាយ ។ កុមារមួយចំនួនដែលអាចស្តាប់ឮបានតិចតួច អាចរៀននិយាយ និងអានដោយមើលមាត់ ។ កុមារផ្សេងៗទៀតប្រាស្រ័យទាក់ទង់បានល្អបំផុត ដោយធ្វើសញ្ញានឹងដៃរបស់ពួកគេ ។ កុមារថ្លង់តូចៗអាចរៀនភាសាសញ្ញាបានយ៉ាងងាយ និងតាមធម្មតា ដូចគ្នានឹងកុមារស្តាប់ឮរៀនភាសានិយាយអញ្ចឹងដែរ ។



ដើម្បីឱ្យមានអារម្មណ៍ល្អចំពោះខ្លួនឯង និងដើម្បីឱ្យមានចំណែកអ្វីមួយដែលជារបស់ខ្លួន ការជួបជុំគ្នារបស់កុមារថ្លង់ និងការជួបជុំនឹងមនុស្សថ្លង់ពេញវ័យ ជាការសំខាន់ណាស់សំរាប់កុមារថ្លង់ ។ នៅក្នុងសហគមន៍អាចមានមនុស្សថ្លង់ម្នាក់ ដែលអាចជួយបង្រៀនភាសាសញ្ញាដល់កុមារថ្លង់ ។

គ្រួសារមួយចំនួន អាចបញ្ជូនកូនរបស់ពួកគេទៅសាលារៀនពិសេសសំរាប់កុមារថ្លង់ ។ គ្រួសារផ្សេងៗទៀតបង្រៀនកូននៅផ្ទះ ។ កុមារមួយចំនួនត្រូវបានជួយជ្រោមជ្រែង និងផ្តល់ឧបករណ៍ជំនួយការស្តាប់ពីគ្លីនិក ហើយរៀនអានតាមបបូរមាត់ ។ ទោះបីជាអ្នកប្រើប្រាស់ការប្រាស្រ័យទាក់ទងប្រភេទណាក៏ដោយ សៀវភៅនេះនឹងព្យាយាមជួយអ្នក ដើម្បីអាចឱ្យអ្នកប្រាស្រ័យទាក់ទងបានជាមួយកូនៗរបស់អ្នក ។

ក្រុមគ្រួសារនីមួយៗ មានរឿងរ៉ាវផ្ទាល់រៀងៗខ្លួន អំពីការលំបាកដែលពួកគេបានជួបប្រទះ និងអ្វីៗដែលពួកគេបានធ្វើដើម្បីជួយកូនរបស់ខ្លួន ។ ការចែករំលែករឿងរ៉ាវទាំងនេះ អាចជួយឱ្យក្រុមគ្រួសារទាំងឡាយចេះរកវិធីនានា ដើម្បីជួយកូនរបស់ពួកគាត់រៀនសូត្រ និងមានអារម្មណ៍កក់ក្តៅ ។

